# ប្រកាស

## ស្តីពី

## គោលការណ៍ណែនាំ និង
## នីតិវិធីរបស់គណៈកម្មការសុរិយោដី

๑๕๒๒

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ : ១១២ ដនសប/ប្រក

# ប្រកាស
# ស្តីពី
# គោលការណ៍ណែនាំ និង នីតិវិធី
# របស់គណៈកម្មការសុរិយោដី

## រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យ លេខ ៦២ អនក្រ/បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យ លេខ ៤៦ អនក្រ/បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និង សៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យ លេខ ៤៧ អនក្រ/បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី
- បានឃើញអនុក្រឹត្យ លេខ ៤៨ អនក្រ/បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ
- បានឃើញប្រកាស លេខ ៧៦ ប្រក/ដនស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ១៩៩៩ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ ...៤

របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង និង តួនាទីភារកិច្ចរបស់បណ្ណាការិយាល័យក្រោមឱវាទ

- តាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

## ស ំ រេ ច

### ១. និយមន័យ

**ប្រការ ១ :-**

ប្រកាសនេះកំណត់នីតិវិធីនៃការដាក់ពាក្យប្តឹង ការសម្រុះសម្រួល និង ការសំរេចលើបញ្ហាវិវាទដីធ្លីដែលបានប្តឹងទៅគណៈកម្មការសុរិយោដីគ្រប់ថ្នាក់ ។

**ប្រការ ២ :-**

គណៈកម្មការសុរិយោដីថ្នាក់ស្រុកខណ្ឌ (គសសខ) គឺជាគណៈកម្មការដែលបានបង្កើតឡើងដោយអនុលោមតាមមាត្រា៤ និង មាត្រា ៥ នៃអនុក្រឹត្យ លេខ ៤៧ អនក្រ/បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ។

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង (គសខក) គឺជាគណៈកម្មការដែលបានបង្កើតឡើងដោយអនុលោមតាមមាត្រា៣ និង មាត្រា ១២ នៃអនុក្រឹត្យលេខ ៤៧ អនក្រ/បក ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី។

គណៈកម្មការសុរិយោដីថ្នាក់ជាតិ (គសជ) គឺជាគណៈកម្មការដែលបានបង្កើតឡើងដោយអនុលោមតាមមាត្រា៣ និងមាត្រា១៧ នៃអនុក្រឹត្យលេខ ៤៧ អនក្រ/បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី។

" គណៈកម្មការរដ្ឋបាល " គឺជាគណៈកម្មការដែលបានបង្កើតឡើងដើម្បីដឹកនាំការចុះបញ្ជីដីធ្លីជាប្រព័ន្ធនៅក្នុងតំបន់វិនិច្ឆ័យ ។ ភារកិច្ចមួយនៃគណៈកម្មការនេះ គឺធ្វើការដោះស្រាយវិវាទដីធ្លីដែលកើតមាននៅក្នុងអំឡុងពេលនៃការចុះបញ្ជី

មានលក្ខណៈជាប្រព័ន្ធស្របតាមមាត្រា ៣ នៃអនុក្រឹត្យ លេខ ៤៦ អនក្រ/បក ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និង សៀវភៅគោលបញ្ជីដីធ្លី ។

" ដីដែលមិនទាន់បានចុះបញ្ជីសុរិយោដី " គឺជាក្បាលដីទាំងឡាយដែលមិនទាន់បានចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ ឬ មានលក្ខណៈដាច់ដោយដុំស្របតាមច្បាប់ភូមិបាលឆ្នាំ២០០១ ។

"បុគ្គល" រួមមាន រូបវន្តបុគ្គល ឬ នីតិបុគ្គល ។

" ដើមបណ្តឹង" គឺជាជនដែលធ្វើការប្តឹងទាមទារអោយមានការដោះស្រាយវិវាទដោយអនុលោមតាមប្រកាសនេះ ។

" ចុងបណ្តឹង" គឺបុគ្គលដែលជំទាស់ទៅនឹងដើមបណ្តឹង ។

## ២. ការចាប់ផ្តើមដំណើរការដោះស្រាយវិវាទ

**ប្រការ ៣ :-**

បុគ្គលទាំងឡាយដែលទាមទារកម្មសិទ្ធិ (ឬ សិទ្ធិកម្មសិទ្ធិ) ឬភោគៈ (ឬ សិទ្ធិភោគៈ) លើដីមិនទាន់បានចុះបញ្ជីសុរិយោដី ហើយដីនោះមានបុគ្គលម្នាក់ ឬច្រើននាក់ផ្សេងទៀតបានទាមទារមួយផ្នែកឬទាំងមូលដែរ អាចដាក់ពាក្យបណ្តឹងទៅគណៈកម្មការ សុរិយោដីថ្នាក់ស្រុក ឬ ខណ្ឌ ដែលដីនោះស្ថិតនៅ ។

**ប្រការ ៤ :-**

បុគ្គលដែលប្តឹងទាមទារធ្វើជាកម្មសិទ្ធិករ ឬ ភោគីនៃដីត្រូវដាក់ពាក្យបណ្តឹង លើកលែងតែក្នុងករណីដែលជននោះជាអសមត្ថជន ។ ក្នុងករណីនេះ អ្នកតំណាងស្របច្បាប់របស់ជននោះ អាចដាក់ពាក្យបណ្តឹងក្នុងនាមជននោះបាន ។

**ប្រការ ៥ :-**

បណ្តឹងទាមទារ ត្រូវធ្វើតាមទម្រង់បែបបទនៃពាក្យបណ្តឹង ដូចមាននៅក្នុងឧបសម្ព័ន្ធទី ១នៃប្រកាសនេះ ។ ដើមបណ្តឹង អាចទទួលយកទម្រង់បែបបទនៃពាក្យបណ្តឹងនេះពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ឬអាចធ្វើទម្រង់បែបបទនៃពាក្យបណ្តឹងរបស់ខ្លួនបាន អោយតែទម្រង់បែបបទនោះមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងទម្រង់បែប បទនៃពាក្យបណ្តឹង ដូចមាន កំណត់នៅក្នុងឧបសម្ព័ន្ធទី ១ ។

ពាក្យបណ្តឹង ត្រូវបញ្ចូលពត៌មានស្តីពីដើមបណ្តឹងដូចតទៅ : ឈ្មោះ សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត ភេទ ឈ្មោះសហព័ទ្ធ (ប្តី-ប្រពន្ធ) កូន ឃុំ ស្រុក ខេត្ត មុខរបរ អាស័យដ្ឋានបច្ចុប្បន្ន ទីតាំងដីវិវាទ សេចក្តីពណ៌នាពីវិវាទដោយមានភាពជាក់លាក់តាមដែលអាចធ្វើទៅបាន ឯកសារពាក់ព័ន្ធនានា ឈ្មោះ និង អាស័យដ្ឋានរបស់ចុងបណ្តឹង ។ ដើមបណ្តឹងត្រូវផ្តល់រាល់ពត៌មានដូចបានតំរូវនៅក្នុងទម្រង់បែបបទបណ្តឹងហើយត្រូវចុះកាលបរិច្ឆេទ និង ចុះហត្ថលេខា ឬ ផ្តិតមេដៃលើពាក្យបណ្តឹងនោះ ។

ដើមបណ្តឹងត្រូវ ផ្តល់បែបបទបណ្តឹងដែលបំពេញរួចយ៉ាងហោចចំនួន ០៤ ច្បាប់ ដែលមួយច្បាប់សំរាប់រក្សាទុកក្នុងសំណុំឯកសាររបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌមួយច្បាប់សំរាប់បិទផ្សាយ មួយច្បាប់សំរាប់បញ្ជូនទៅអោយដើមបណ្តឹងវិញ និងមួយច្បាប់ទៀតសំរាប់ចុងបណ្តឹង ។ ក្នុងករណីមានចុងបណ្តឹងច្រើននាក់មានឈ្មោះនៅក្នុងពាក្យបណ្តឹងនោះដើមបណ្តឹងត្រូវផ្តល់ឯកសារពាក្យបណ្តឹងមួយច្បាប់ៗដល់ចុងបណ្តឹងម្នាក់ៗដែលមានឈ្មោះ ។

**ប្រការ ៦ :-**

នៅពេលទទួលពាក្យបណ្តឹង គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវបើកសំណុំរឿង ហើយត្រូវកំណត់លេខដើម្បី ជាការសំគាល់សំណុំរឿងវិវាទតាម ខេត្ត និងស្រុក ដែលដីវិវាទនោះស្ថិតនៅ ។

មន្ត្រីទទួលពាក្យបណ្តឹង ត្រូវចុះលេខសំគាល់សំណុំរឿងវិវាទ ចុះហត្ថលេខា និង បោះត្រាផ្លូវការលើទម្រង់បែបបទនៃពាក្យបណ្តឹងច្បាប់ដើម ហើយផ្តល់ឯកសារដែលបានចុះបញ្ជីមួយច្បាប់ទៅដើមបណ្តឹងវិញ ។ ឯកសារនេះគឺជាភស្តុតាងនៃការដាក់ ពាក្យបណ្តឹងរបស់ដើមបណ្តឹង ។

មន្ត្រីទទួលពាក្យបណ្តឹង ត្រូវថតចម្លងឯកសារនានាដែលបានភ្ជាប់មកជាមួយពាក្យបណ្តឹងហើយត្រូវបញ្ចូលឯកសារថតចម្លងទាំងនេះទៅក្នុងសំណុំរឿងផ្លូវការ ។ មន្ត្រីទទួលពាក្យបណ្តឹង ត្រូវបង្វិលឯកសារច្បាប់ដើមទៅអោយដើមបណ្តឹងវិញ ។

**ប្រការ ៧ :-**

ក្នុងរយៈពេលប្រាំថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលពាក្យបណ្តឹង គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌត្រូវបិទផ្សាយពាក្យបណ្តឹងនោះរួមជាមួយនិងសេចក្តីជូនដំណឹងអំពីបណ្តឹងរៀបចំឡើងដោយគណៈកម្មការសុរិយោដីថ្នាក់ស្រុកខណ្ឌដែលបញ្ជាក់ថាពាក្យបណ្តឹងនោះបានចុះបញ្ជីហើយ ។ សេចក្តីជូនដំណឹងពីបណ្តឹងត្រូវធ្វើឡើងតាមទម្រង់បែបបទដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី ២ ។ សេចក្តីជូនដំណឹងនោះ ត្រូវអញ្ជើញបុគ្គលគ្រប់រូបដែលមានផលប្រយោជន៍នៅក្នុងដីវិវាទអោយឆ្លើយតបចំពោះពាក្យបណ្តឹងក្នុងរយៈពេល៣០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការបិទផ្សាយសេចក្តីជូនដំណឹង និង ពាក្យបណ្តឹងនោះ ។

ពាក្យបណ្តឹង និង សេចក្តីជូនដំណឹងអំពីពាក្យបណ្តឹងមួយច្បាប់ត្រូវបិទផ្សាយនៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក ខណ្ឌ ហើយសាធារណជនអាចចូលមើលបានដោយសេរីក្នុងអំឡុងពេលម៉ោងធ្វើការធម្មតា ។ ត្រូវអនុញ្ញាតឱ្យជនគ្រប់រូបមើលសេចក្តីជូនដំណឹងដែលបាន បិទផ្សាយនោះដើម្បីអោយដឹងថា តើខ្លួនមានផលប្រយោជន៍នៅក្នុងវិវាទនោះឬទេ ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវបិទសេចក្តីជូនដំណឹងមួយច្បាប់នៅលើទីតាំងដីដែលមានវិវាទ ។

ក្នុងរយៈពេលប្រាំថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យបណ្តឹងគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវជូនដំណឹងដល់ចុងបណ្តឹងដែលមានឈ្មោះនៅក្នុងពាក្យបណ្តឹងអំពីការប្តឹងទាមទារនោះ តាមរយៈការផ្តល់ដល់ចុងបណ្តឹង នូវពាក្យបណ្តឹងដែលបំពេញរួចម្នាក់មួយច្បាប់ ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវជូនដំណឹងដល់ចុងបណ្តឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការឆ្លើយតបចំពោះបណ្តឹងទាមទារនោះ ហើយត្រូវជូនដំណឹងដល់ចុងបណ្តឹងអំពីសិទ្ធិចូលរួមប្រជុំជាមួយគណៈកម្មការសុរិយោដី ថ្នាក់ស្រុក ខណ្ឌ ដើម្បីពិគ្រោះយោបល់អំពីបណ្តឹង ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវផ្តល់អោយចុងបណ្តឹងនូវសេចក្តីសង្ខេបអំពីរបៀបសម្រុះសម្រួល ។

ប្រការ ៨ :-

ចុងបណ្តឹងដែលមានឈ្មោះក្នុងពាក្យបណ្តឹង អាចឆ្លើយតបចំពោះបណ្តឹងតាមរយៈការដាក់សំណុំបែបបទឆ្លើយតបចំពោះបណ្តឹងដែលមានកំណត់ក្នុងឧបសម្ព័ន្ធទី ៤ ទៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ក្នុងរយៈពេល ៣០ថ្ងៃបន្ទាប់ពីបានទទួលឯកសារចម្លងនៃពាក្យបណ្តឹងពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវផ្តល់ដល់ចុងបណ្តឹងនូវឯកសារថតចម្លងមួយច្បាប់នៃពាក្យបណ្តឹង និង សេចក្តីសង្ខេបអំពីរបៀប សម្រុះសម្រួល ។

រាល់បុគ្គលផ្សេងទៀតដែលមានផលប្រយោជន៍នៅក្នុងដីវិវាទនេះ ត្រូវដាក់បែបបទឆ្លើយតបចំពោះបណ្តឹងក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីពេលដែលសេចក្តីជូនដំណឹងអំពីបណ្តឹងត្រូវបានបិទផ្សាយនៅការិយាល័យគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ និង នៅលើទីតាំងដីវិវាទដោយគិតតាមកាលបរិច្ឆេទនៃសេចក្តីជូនដំណឹងមួយណាដែលបិទក្រោយគេ ។

ចុងបណ្តឹង អាចទទួលបានទម្រង់បែបបទឆ្លើយតបចំពោះបណ្តឹងពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ឬអាចដាក់ទម្រង់បែបបទរបស់ខ្លួនផ្ទាល់បាន អោយតែទម្រង់បែបបទនោះមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងទម្រង់បែបបទដូចមាន កំណត់ក្នុងឧបសម្ព័ន្ធទី ៤ ។

ចុងបណ្តឹងនោះ ត្រូវផ្តល់ទម្រង់បែបបទឆ្លើយតបចំពោះបណ្តឹងដែលបំពេញរួចយ៉ាងហោចចំនួន០៤ច្បាប់ ដែលមួយច្បាប់សំរាប់រក្សាទុកក្នុងសំណុំរឿងរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មួយច្បាប់សំរាប់បិទផ្សាយ មួយច្បាប់សំរាប់បញ្ជូនទៅអោយដើមបណ្តឹងវិញ និងមួយច្បាប់ទៀតសំរាប់ចុងបណ្តឹង ។ ក្នុងករណីមានចុងបណ្តឹង ឬដើមបណ្តឹងច្រើននាក់មានឈ្មោះនៅក្នុងពាក្យបណ្តឹង នោះចុងបណ្តឹងត្រូវផ្តល់ឯកសារចម្លងឆ្លើយតបចំពោះបណ្តឹងដល់ចុងបណ្តឹង និង/ឬ ដើមបណ្តឹង ដែលមានឈ្មោះ ម្នាក់ៗមួយច្បាប់ ។

ចុងបណ្តឹង ត្រូវបង្ហាញឯកសារពាក់ព័ន្ធនៅពេលដាក់ពាក្យឆ្លើយតបចំពោះបណ្តឹង ។ មន្ត្រីទទួលពាក្យត្រូវថតចម្លងឯកសារដែលបានដាក់ភ្ជាប់មកជាមួយនោះ រួចហើយបង្វិលឯកសារច្បាប់ដើមទាំងនោះទៅអោយចុងបណ្តឹងវិញ ។

ពាក្យឆ្លើយតប និង ឯកសារដែលបានភ្ជាប់មកជាមួយនោះ ត្រូវបញ្ចូលទៅក្នុងសំណុំរឿងវិវាទផ្លូវការ ។

## ប្រការ ៩ :-

គ្មានករណីណាមួយដែលដើមបណ្តឹង ឬ ចុងបណ្តឹងណាម្នាក់ត្រូវបានគេសុំ ឬតម្រូវអោយបង់ថ្លៃដាក់ពាក្យបណ្តឹង ឬពាក្យឆ្លើយតបឡើយ ។

# ៣ . ការស៊ើបអង្កេត

## ប្រការ ១០ :-

រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវចាត់មន្ត្រីសុរិយោដីចុះទៅធ្វើការស៊ើបអង្កេតបណ្តឹង ។ អ្នកស៊ើបអង្កេតត្រូវចុះទៅជួបភាគីទាំងអស់ កត់ត្រាសេចក្តីអះអាងរបស់ភាគី និងប្រមូលរាល់ពត៌មានទាក់ទងផ្សេងៗ និង ភស្តុតាងផ្សេងៗទាក់ទងនឹងវិវាទនោះ រួមទាំងពត៌មានដែលចាំបាច់ដើម្បីកំណត់ថា តើភាគីពាក់ព័ន្ធទាំងអស់ក្នុងវិវាទដីធ្លីនេះមានឈ្មោះនៅក្នុងសំណុំរឿងវិវាទដែលបានដាក់ជូនគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ហើយឬនៅ ថាជាភាគីនៃវិវាទឬ អត់ ។ ការស៊ើបអង្កេតត្រូវចាប់ផ្តើមអោយបានឆាប់បំផុតតាមដែលអាចធ្វើទៅបានបន្ទាប់ពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ បានទទួលពាក្យបណ្តឹង ។

## ប្រការ ១១ :-

រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវវាស់វែង និងកំណត់ព្រំដីដែលមានវិវាទ ស្របតាមនីតិវិធីដូចមានចែងនៅក្នុងអនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ។ ប្រសិនបើរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ មិនអាចបំពេញការ

ទទួលខុសត្រូវនេះបានដោយសារតែខ្លួនពុំមានសមត្ថភាពបច្ចេកទេសគ្រប់គ្រាន់ រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ នោះអាចស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាល សុរិយោដីខេត្ត ក្រុង ។

**ប្រការ ១២ :-**

អ្នកស៊ើបអង្កេតមានសិទ្ធិជួបបុគ្គលណាម្នាក់ ឬ មានសិទ្ធិមើលឯកសារដែលកំណត់ថាចាំបាច់សំរាប់ការស៊ើបអង្កេតឱ្យបានពេញលេញ ។

បុគ្គលទាំងឡាយរួមទាំងសាក្សីរបស់ភាគី និង សាក្សីឯទៀតត្រូវជួបជាមួយអ្នកស៊ើបអង្កេត ប្រសិនបើខ្លួនត្រូវបានស្នើសុំដោយអ្នកស៊ើបអង្កេត ហើយអ្នកស៊ើបអង្កេតត្រូវកំណត់ការប្រជុំតាមពេលវេលា និង ទីកន្លែងដែលងាយស្រួលចំពោះអ្នកពាក់ព័ន្ធ ទាំងឡាយ ។

ឯកសារច្បាប់ដើមទាំងឡាយត្រូវបង្វិលទៅអោយអ្នកដែលផ្តល់ឯកសារនោះវិញ ហើយច្បាប់ថតចម្លងនៃឯកសារនោះត្រូវរក្សាទុកនៅក្នុងកំណត់ហេតុផ្លូវការនៃវិវាទ ។

**ប្រការ ១៣ :-**

ភាគីវិវាទនីមួយៗ ត្រូវមានវត្តមានក្នុងពេលធ្វើការស៊ើបអង្កេតដល់ទីកន្លែង និងត្រូវចាំទ់ស្មានសោហ៊ុយដែលទាក់ទងទៅនឹងការស៊ើបអង្កេតម្តងទៀតក្នុងករណីដែលមានភាគីណាមួយអវត្តមាន ។ បើអវត្តមានរបស់ភាគីមួយបង្កឡើងដោយសារទង្វើមិនសមរម្យរបស់ភាគីឯទៀត នោះភាគីដែលមានកំហុសត្រូវចេញសោហ៊ុយសំរាប់ថ្លៃការស៊ើបអង្កេតជាថ្មីនោះ។

**ប្រការ ១៤ :-**

ភាគីវិវាទ អាចផ្តល់ភស្តុតាង និងសាក្សីបាន ហើយរាល់ភស្តុតាង និងចម្លើយរបស់សាក្សីទាំងនោះត្រូវក្លាយជាផ្នែកមួយនៃកំណត់ហេតុផ្លូវការនៃវិវាទ ។

អ្នកស៊ើបអង្កេត ត្រូវទទួលយក និង បញ្ចូលជាផ្នែកមួយនៃកំណត់ហេតុផ្លូវការនៃវិវាទនូវរាល់ភស្តុតាងដែលត្រូវបានផ្តល់ដោយភាគី ឬ ដែលត្រូវបានប្រមូលក្នុងអំឡុងពេលធ្វើការស៊ើបអង្កេត ។ ភស្តុតាងទាំងនោះមានជាអាទិ៍ :

- ផែនទី ឬ កំណត់ហេតុអង្កេតវាស់វែង
- ឯកសារសំគាល់ការកាន់កាប់ដី
- រូបថត របស់ភាគីកាន់កាប់ដី ៤.ស

- សំបុត្រស្នាមផ្សេងៗដែលបានធ្វើដោយមានចុះអាស័យដ្ឋាននៃដីនោះ សំបុត្រកំណើត ឬ ប័ណ្ណគ្រួសារ ដែលបង្ហាញពីវត្តមានយូរអង្វែងនៅលើដីនោះ ឬសៀវភៅសម្រង់ស្ថិតិរបស់ប្រធានភូមិ
- ចម្លើយរបស់អ្នកជិតខាងថា តើនរណាដែលបានរស់នៅលើដីនោះ
- បង្កាន់ដៃទទួលប្រាក់ ឬ ឯកសារផ្សេងៗទាក់ទងទៅនឹងការទិញដី ឬ ការផ្ទេរសិទ្ធិនៃដីនោះ ។

**ប្រការ ១៥ :-**

អ្នកស៊ើបអង្កេត ត្រូវសម្ភាសន៍សាក្សីទាំងឡាយដែលផ្តល់ដោយភាគីវិវាទ ឬ ដែលអ្នកស៊ើបអង្កេតចាត់ទុកថាចាំបាច់ដើម្បីបញ្ជាក់អង្គហេតុនៃវិវាទ ។ សាក្សីនីមួយៗត្រូវធ្វើសម្បថ ថានឹងនិយាយតែការពិតហើយរាយការណ៍រាល់ព្រឹត្តិការណ៍ និង អង្គហេតុទាំងឡាយដែលសាក្សីយល់ និងជឿថាត្រឹមត្រូវ ។

អ្នកស៊ើបអង្កេត ត្រូវពិនិត្យសាក្សីនីមួយៗដើម្បីកំណត់អំពីភាពគួរអោយជឿបាននៅក្នុងចម្លើយរបស់សាក្សី តើសាក្សីដឹងគិតណា ការដឹងរបស់សាក្សីផ្អែកលើព្រឹត្តិការណ៍ទាំងឡាយដែលបានសង្កេតឃើញដោយខ្លួនឯងផ្ទាល់ ឬដោយគ្រាន់តែបានឮពីអ្នកណាម្នាក់ផ្សេងទៀត ។ ចម្លើយសាក្សី និង ការសម្ភាសន៍សាក្សីត្រូវទុកជាផ្នែកមួយនៃកំណត់ហេតុផ្លូវការនៃវិវាទ ។

**ប្រការ ១៦ :-**

អ្នកស៊ើបអង្កេត ត្រូវរៀបចំរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីលទ្ធផលនៃការស៊ើបអង្កេតដោយអនុលោមតាមទំរង់នៃស្តង់ដារដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី ៥។ លទ្ធផលទាំងនេះត្រូវរួមបញ្ចូលនូវ ព្រំដីវិវាទ ផែនទី ឬ គំនូសតាងពាក់ព័ន្ធ សេចក្តីសង្ខេបអំពីចម្លើយរបស់សាក្សី និងចម្លើយលាយលក្ខណ៍អក្សរ សេចក្តីសង្ខេបនៃរាល់ឯកសារពាក់ព័ន្ធទៅនឹងដីវិវាទដែលមានការអះអាងដោយអ្នកស៊ើបអង្កេត ឬ ដែលបានទទួលពីភាគីវិវាទ។

## ៤. ការកំណត់អំពីសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដី ថ្នាក់ស្រុក ខណ្ឌ ក្នុងការសម្រុះសម្រួលវិវាទ

**ប្រការ ១៧ :-**

បន្ទាប់ពីការស៊ើបអង្កេតត្រូវបានបញ្ចប់ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវកំណត់ថាតើគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានសមត្ថកិច្ចធ្វើការសម្រុះសម្រួលវិវាទនោះដែរឬទេ ។

វិវាទទាំងឡាយត្រូវ សម្រុះសម្រួលដោយគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ លើកលែងតែប្រធានគណៈកម្ម-

ការស៊ីរិយោជីថ្នាក់ស្រុក ខណ្ឌ កំណត់ថាវិវាទនោះមិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់គណៈកម្មការស៊ីរិយោជីថ្នាក់ស្រុក ខណ្ឌ ដោយសំអាងលើហេតុផលនានាដូចមានចែងនៅក្នុងប្រការ ១៨ នៃប្រកាសនេះ ឬ ដោយវិវាទនោះកើតឡើងដោយសារភាគីមួយ ឬច្រើនប្តឹងផ្អែកលើមូលដ្ឋានមិនច្បាស់លាស់ដូចមានចែងក្នុងប្រការ ១៩ នៃប្រកាសនេះ ។

**ប្រការ ១៨ :-**

ប្រសិនបើវិវាទមិនអាចដោះស្រាយបានដោយសមធម៌នៅថ្នាក់ស្រុក ខណ្ឌ គណៈកម្មការស៊ីរិយោជីថ្នាក់ស្រុក ខណ្ឌ ត្រូវដាក់សំណុំរឿងវិវាទនោះដោយផ្ទាល់ជូនទៅគណៈកម្មស៊ីរិយោជីថ្នាក់ខេត្ត ក្រុង តាមការយល់ឃើញផ្ទាល់របស់ប្រធាន ឬ តាមសំណើរបស់ភាគីវិវាទទាំងសងខាងដូចមានចែងនៅក្នុងមាត្រា ១០ នៃអនុក្រឹត្យលេខ ៤៧ អនក្រ/បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការស៊ីរិយោជី ។

ប្រសិនបើមានភាគីតែម្ខាង ស្នើអោយបញ្ជូនករណីវិវាទនោះទៅគណៈកម្មការស៊ីរិយោជីថ្នាក់ខេត្ត ក្រុង វិវាទនោះត្រូវបញ្ជូនទៅគណៈកម្មការស៊ីរិយោជីថ្នាក់ខេត្ត ក្រុងលើកលែងតែប្រធានគណៈកម្មការស៊ីរិយោជីថ្នាក់ស្រុក ខណ្ឌ យល់ឃើញថាសំណើនោះមិនសមហេតុផល។ ហេតុផលនៃការបដិសេធសំណើនោះរួមមានការកំណត់របស់ប្រធានគណៈកម្ម-ការដែលយល់ថាសំណើនោះធ្វើឡើងគ្រាន់តែដើម្បីឱ្យមានការយឺតយ៉ាវដល់ការដោះស្រាយវិវាទ ឬ បង្កអោយមានការលំបាកដល់ភាគីម្ខាងទៀត និងអាច មានហេតុផលផ្សេងទៀត ។

ប្រសិនបើប្រធានគណៈកម្មការ បដិសេធមិនបញ្ជូនវិវាទនោះដោយផ្ទាល់ទៅគណៈកម្មការស៊ីរិយោជីថ្នាក់ខេត្ត ក្រុង តាមសំណើរបស់ភាគីម្ខាង ប្រធានគណៈកម្មការត្រូវពន្យល់ជាលាយលក្ខណ៍អក្សរអំពីមូលហេតុនៃការបដិសេធសំណើនោះ ហើយការពន្យល់នេះត្រូវតែជាផ្នែកមួយនៃកំណត់ហេតុផ្លូវការនៃវិវាទនោះ ។ ការសម្រុះសម្រួលដែលតម្រូវឱ្យមានការបញ្ជូនករណីវិវាទ ទៅគណៈកម្មការស៊ីរិយោជីថ្នាក់ខេត្ត ក្រុង រួមមាន :

- ជនម្នាក់ទាមទារដីច្រើនក្បាល ដែលជាកម្មវត្ថុនៃការប្តឹងទាមទាររបស់ភាគីតូចតាចមួយចំនួនដែរ
- ភាគីម្ខាងនៃវិវាទគឺជាអាជ្ញាធរមានឋានៈខ្ពស់
- ករណីមានវិវាទពាក់ព័ន្ធទៅនឹងផលប្រយោជន៍របស់ប្រធានគណៈកម្មការថ្នាក់ស្រុក ខណ្ឌ
- វិវាទពាក់ព័ន្ធនឹងដីសាធារណៈរបស់រដ្ឋ ។

ក្នុងករណីណាក៏ដោយ គណៈកម្មការស៊ីរិយោជីថ្នាក់ស្រុក ខណ្ឌ មិនមានសិទ្ធិអំណាចសម្រុះសម្រួលវិវាទដែលទាក់ទងទៅ នឹងដីសាធារណៈរបស់រដ្ឋឡើយ ។

ប្រការ ១៩ :-

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវច្រានចោលបណ្តឹងទាមទារណាដែលមិនត្រឹមត្រូវ ឬ គ្មានមូលដ្ឋាន ឬ ដែលធ្វើឡើងដើម្បីយាយី ឬ បំភិតបំភ័យភាគីម្ខាង ។ ការច្រានចោលបណ្តឹងមិនមែនជាប្រការគួរលើកទឹកចិត្តអោយធ្វើនោះទេលើកលែងតែក្នុងករណីចាំបាច់ដើម្បីរារាំងភាពអយុត្តិធម៌តែប៉ុណ្ណោះ ។

បណ្តឹងមិនត្រឹមត្រូវ គឺបណ្តឹងដែលខ្វះមូលដ្ឋានអង្គហេតុសមហេតុផលឬទាក់ទងទៅនឹងវិវាទដែលស្ថិតនៅក្រៅវង្វង់សមត្ថកិច្ចនៃច្បាប់ភូមិបាលឆ្នាំ ២០០១ ។ លក្ខខណ្ឌនៃបណ្តឹងដែលមិនមានមូលដ្ឋានអង្គហេតុគ្រប់គ្រាន់ មានជាអាទិ៍ :

- សាក្សី ឬ ភស្តុតាងរបស់ភាគីម្ខាង បង្ហាញថាមានលក្ខណៈក្លែងបន្លំ ឬ ខុស ដូចជា សាក្សីរបស់ភាគីម្ខាងដកពាក្យចម្លើយរបស់ខ្លួនវិញ ឬ ផ្តល់ចម្លើយដែលប្រឆាំងដោយត្រង់ទៅនឹងការទាមទាររបស់ភាគីម្ខាង
- ការស៊ើបអង្កេត និងពត៌មានផ្សេងទៀតដែលភាគីស្នើឡើងមិនបង្ហាញភស្តុតាងណាមួយដែលគាំទ្រដល់ការទាមទាររបស់ភាគីដូចមានក្នុងពាក្យបណ្តឹង ។

ក្នុងករណីបណ្តឹងត្រូវបានច្រានចោល ភាគីអាចប្តឹងតវ៉ាទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

ភាគីណាមួយដែលធ្វើការទាមទារដោយគ្មានមូលដ្ឋាន ឬ មិនមានលក្ខណៈច្បាប់ ត្រូវចេញសោហ៊ុយថ្លៃដំណើរការវិវាទដែលបានចំណាយមកដល់ពេលនោះ និង ត្រូវទទួលទោសព្រហ្មទណ្ឌបន្ថែមទៀតដោយអនុលោមតាមច្បាប់ភូមិបាល ២០០១ និង ច្បាប់ផ្សេងៗទៀត ។ ត្រូវរារាំងមិនអោយភាគីដែលដាក់ពាក្យបណ្តឹងមិនត្រឹមត្រូវ ប្តឹងទាមទារជាថ្មីម្តងទៀត ។

ភាគីណាដែលបង្ហាញភស្តុតាងក្លែងបន្លំ ត្រូវដកចេញពីដំណើរការវិវាទ ហើយភស្តុតាងត្រូវដកចេញពីកំណត់ហេតុផ្លូវការនៃវិវាទ និងត្រូវទទួលទោសព្រហ្មទណ្ឌបន្ថែមទៀតដូចមានចែងនៅក្នុងច្បាប់ភូមិបាល ២០០១ និងច្បាប់ផ្សេងៗទៀត។ ភាគីណាដែលត្រូវបានរកឃើញថា បានធ្វើការក្លែងបន្លំភស្តុតាង ឬឯកសារអាចទទួលទោសព្រហ្មទណ្ឌដូចមានចែងនៅក្នុងច្បាប់ភូមិបាល ឆ្នាំ ២០០១ និង ច្បាប់ផ្សេងៗទៀត។

## ៥. ការសម្រុះសម្រួលរបស់គណៈកម្មការ សុរិយោដីថ្នាក់ស្រុក ខណ្ឌ

ប្រការ ២០ :-

បន្ទាប់ពីបញ្ចប់ការស៊ើបអង្កេត មិនតិចជាង ៣០ ថ្ងៃបន្ទាប់ពីសេចក្តីជូនដំណឹងពីបណ្តឹងត្រូវបានបិទផ្សាយដូចមានចែងក្នុងប្រការ ៧នៃប្រកាសនេះប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវរៀបចំប្រជុំគណៈកម្មការសុរិយោដី

ថ្នាក់ស្រុក ខណ្ឌដើម្បីសំរេចលើដំណើរការសម្រុះសម្រួលវិវាទ ។ កិច្ចប្រជុំត្រូវធ្វើឡើងនៅលើដីវិវាទ ឬកន្លែងដែលនៅជិតដីវិវាទតាមដែលអាចធ្វើទៅបាន ។

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវអញ្ជើញតំណាងអាជ្ញាធរដែនដីស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ និង/ឬ ចាស់ព្រឹទ្ធាចារ្យនៅក្នុងមូលដ្ឋានឱ្យចូលរួមជាសមាជិកអាដហុករបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដើម្បីសម្រុះសម្រួលវិវាទ ។ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ គប្បីយកចិត្តទុកដាក់បញ្ចូលស្ត្រីជាសមាជិកគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវអញ្ជើញភាគីវិវាទមកចូលរួមការប្រជុំរដ្ឋបាលយ៉ាងហោច ៥ ថ្ងៃនៃថ្ងៃធ្វើការមុនថ្ងៃប្រជុំនេះ ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវផ្តល់ដល់ភាគីទាំងអស់នូវសេចក្តីសង្ខេបអំពីរបៀបសម្រុះសម្រួល និងត្រូវពន្យល់អំពីពត៌មាននេះដល់ភាគីទាំងអស់ ។

នៅពេលប្រជុំរដ្ឋបាលនេះ ភាគីត្រូវជូនដំណឹងដល់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ អំពីការស្នើសុំរបស់ខ្លួនឱ្យបញ្ជូនសំណុំរឿងវិវាទនេះទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវធ្វើការជំទាស់ចំពោះវិវាទអំពីផលប្រយោជន៍នានា និង ធ្វើការព្រមព្រៀងជាឯកច្ឆ័ន្ទលើសមាសភាពអ្នកសម្រុះសម្រួលដូចមានចែងក្នុង ប្រការ ២២ នៃប្រកាសនេះ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌត្រូវដោះស្រាយរាល់វិវាទអំពីផលប្រយោជន៍ និងកំណត់អ្នកសម្រុះសម្រួលវិវាទ ។ បន្ទាប់មក អ្នកសម្រុះសម្រួលត្រូវជួបជាមួយភាគីទាំងឡាយ និង កំណត់ពេលវេលាសំរាប់ការសម្រុះសម្រួលវិវាទ។

**ប្រការ ២១ :-**

ប្រសិនបើ មានសមាជិកណាម្នាក់នៃគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានផលប្រយោជន៍នៅក្នុងវិវាទសមាជិករូបនោះត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទនោះហើយគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវតែងតាំងសមាជិកថ្មីជំនួសវិញ។

ប្រសិនបើ មានវិវាទអំពីផលប្រយោជន៍ជាមួយប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ វិវាទនោះត្រូវដាក់ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

ភាគីអាចប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរចំពោះការចូលរួមរបស់សមាជិកណាម្នាក់នៃគណៈកម្មការសុរិយោដីថ្នាក់ស្រុកខណ្ឌដោយផ្អែកលើមូលដ្ឋាននៃវិវាទអំពីផលប្រយោជន៍របស់សមាជិក ។ សមាជិកដទៃទៀតនៃគណៈកម្មការត្រូវសំរេចថាតើ សមាជិករូបនោះមានវិវាទអំពីផលប្រយោជន៍ដែលរាំងមិនឱ្យសមាជិករូបនោះចូលរួមនៅក្នុងការដោះស្រាយវិវាទ ឬទេ ។ វិវាទអំពីផលប្រយោជន៍ដែលចោទប្រកាន់ចំពោះប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវដោះស្រាយតាមនីតិវិធីដូចមានកំណត់ក្នុងប្រការ ១៨ នៃប្រកាសនេះ ។

**ប្រការ ២២ :-**

ភាគីវិវាទ អាចជ្រើសរើសអ្នកសម្រុះសម្រួលក្នុងចំណោមសមាជិកអាជ្ញាធរ និងសមាជិកអចិន្ត្រៃយ៍នៃគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ នៅក្នុងលក្ខខណ្ឌតែមួយគត់គឺភាគីទាំងអស់ព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរក្នុងការប្រើអ្នកសម្រុះសម្រួលជាក់លាក់នោះ ។

ក្នុងករណីភាគីវិវាទមិនអាចព្រមព្រៀងគ្នាលើសមាសភាពអ្នកសម្រុះសម្រួលជាក់លាក់ណាមួយមកពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌទេនោះ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវចាត់តាំងអ្នកសម្រុះសម្រួលចេញពីសមាជិកអាជ្ញាធរ និង សមាជិកអចិន្ត្រៃយ៍នៃគណៈកម្មការ ។

ក្រុមអ្នកសម្រុះសម្រួលមានសមាជិក ៣ រូប ដែលមានម្នាក់ជាប្រធាន ត្រូវសម្រុះសម្រួលវិវាទ ។

សមាជិកទាំងឡាយនៃក្រុមអ្នកសម្រុះសម្រួល យ៉ាងហោចណាស់ត្រូវមានសមាជិកម្នាក់ដែលបានទទួលការបណ្តុះបណ្តាល ឬមានបទពិសោធន៍នៅក្នុងការសម្រុះសម្រួលវិវាទ និង មានសមាជិកម្នាក់ជាអ្នកដឹងអំពីស្ថានភាព និងសភាពការណ៍នៅក្នុង មូលដ្ឋាន ។

ប្រសិនបើ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ កំណត់ថាគ្មានសមាជិកណាម្នាក់នៃសមាជិកក្រុមអ្នកសម្រុះសម្រួលមានបទពិសោធន៍ ឬ ការបណ្តុះបណ្តាលនៅក្នុងដំណើរការសម្រុះសម្រួលទេនោះ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ អាចស្នើសុំឱ្យគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ចាត់តាំងអ្នកសម្រុះសម្រួលដែលបានទទួលការបណ្តុះបណ្តាលអោយចូលរួមនៅក្នុងក្រុមអ្នកសម្រុះសម្រួល ។

**ប្រការ ២៣ :-**

ភាគីវិវាទអាចជ្រើសរើសបុគ្គលម្នាក់តាមជំរើសរបស់ខ្លួនផ្ទាល់ឱ្យជួយខ្លួននៅគ្រប់ថ្នាក់នៃដំណើរការសម្រុះសម្រួល ។ បុគ្គលរូបនេះហៅថាអ្នកជំនួយការភាគី ឬអ្នកជំនួយការមិនអាចតំណាងឱ្យភាគីបានទេ ប៉ុន្តែអាចផ្តល់យោបល់ដល់ភាគីវិវាទបាន ។ អ្នកជំនួយការភាគី អាចបំភ្លឺយោបល់របស់ភាគី និងអាចចូលរួមនៅក្នុងកិច្ចប្រជុំទាំងឡាយជាមួយអ្នក

សម្រុះសម្រួល និងជាមួយភាគីបាន ប៉ុន្តែមិនអាចនិយាយជំនួសភាគីទៅកាន់អ្នកសម្រុះសម្រួល ឬ ភាគីផ្សេងទៀតបានទេ ឬ មិនអាចធ្វើសេចក្តីសំរេចក្នុងនាមភាគីបានឡើយ ។

ប្រសិនបើអ្នកជំនួយការភាគីនោះបំពានវិធាននៃដំណើរការវិវាទ ក្រុមអ្នកសម្រុះសម្រួលត្រូវផ្តល់ការក្រើនរំលឹក និងការព្រមានជាឯកជនម្តងដល់អ្នកជំនួយការនោះ ។ ប្រសិនបើអ្នកជំនួយការនោះបន្តបំពានទៀតក្រុមអ្នកសម្រុះសម្រួលត្រូវហាមឃាត់អ្នកជំនួយការនោះមិនឱ្យចូលរួមនៅក្នុងដំណើរការវិវាទតទៅទៀតឡើយ ។ ប្រសិនបើអ្នកជំនួយការត្រូវបានរាំង ដំណើរការសម្រុះសម្រួលត្រូវផ្អាកមួយរយៈរហូតដល់ភាគីវិវាទជ្រើសរើសអ្នកជំនួយការថ្មីបាន ឬ ព្រមព្រៀងបន្តដំណើរការដោយពុំចាំបាច់មានអ្នកជំនួយការ ។ អ្នកសម្រុះសម្រួលត្រូវផ្តល់អោយភាគីម្ខាងៗនូវឱកាសគ្រប់គ្រាន់ដើម្បីពិគ្រោះយោបល់ជាមួយអ្នកជំនួយការដែលត្រូវបានហាមឃាត់នៅខាងក្រៅកន្លែងធ្វើការសម្រុះសម្រួល ។

**ប្រការ ២៤ :-**

អ្នកសម្រុះសម្រួលត្រូវជួបជាមួយភាគីទាំងឡាយរួមគ្នា ឬ ដាច់ដោយឡែកពីគ្នាប្រសិនបើមានការស្នើសុំដើម្បីពិភាក្សាពីបញ្ហារបស់ភាគី ពន្យល់ករណីវិវាទដល់ភាគីវិវាទដោយផ្អែកលើភស្តុតាង និងពិគ្រោះអំពីលទ្ធភាពដំណោះ-ស្រាយនានាដែលអាចមានចំពោះវិវាទ ។ ការពិគ្រោះត្រូវធ្វើឡើងដោយរក្សាការសំងាត់ក្នុងចំណោមភាគីវិវាទអ្នកជំនួយការរបស់ភាគី និង អ្នកសម្រុះសម្រួលហើយមិនត្រូវយកការពិគ្រោះនេះទៅធ្វើជាផ្នែកមួយនៃកំណត់ហេតុផ្លូវការនៃវិវាទឡើយ ។

អ្នកសម្រុះសម្រួល អាចស្នើដំណោះស្រាយដោយផ្អែកលើការយល់ដឹងរបស់ខ្លួនអំពីបំណងរបស់ភាគីវិវាទលើភស្តុតាងដែលមាន និងផ្អែកលើច្បាប់ពាក់ព័ន្ធប៉ុន្តែអ្នកសម្រុះសម្រួលមិនត្រូវបង្ខំឱ្យអនុវត្តតាមសំណើរបស់ខ្លួន ឬ មិនត្រូវធ្វើសេចក្តីសំរេចលើ វិវាទនោះឡើយ ។ មានតែភាគីវិវាទទេដែលមានសិទ្ធិសំរេច ឬបដិសេធដំណោះស្រាយបាន ។

**ប្រការ ២៥ :-**

អ្នកសម្រុះសម្រួលត្រូវវិភាគភស្តុតាង ដែលប្រមូលបាននៅក្នុងពេលស៊ើបអង្កេតដើម្បីយល់អោយបានពេញលេញអំពីស្ថានភាពនៃវិវាទ ប៉ុន្តែអ្នកសម្រុះសម្រួលមិនត្រូវវាយតំលៃភស្តុតាងក្នុងសមត្ថភាពជាផ្លូវការណាមួយឡើយ ។

អ្នកសម្រុះសម្រួលអាចផ្តល់យោបល់ដល់ភាគីវិវាទ អំពីរបៀបបកស្រាយភស្តុតាងវិវាទ ឬ តំលៃនៃភស្តុតាងអាចត្រូវបានបកស្រាយយ៉ាងណា ប៉ុន្តែយោបល់ទាំងនោះពុំមានតំលៃខាងផ្លូវច្បាប់ និង មិនអាចក្លាយជាលំអានសំរាប់អនុវត្តនៅក្នុងដំណើរការសម្រុះសម្រួល ឬ ការវិនិច្ឆ័យណាមួយឡើយ ។

ការវាយតម្លៃភស្តុតាង អាចបញ្ចូលជាផ្នែកមួយនៃរបាយការណ៍សម្រុះសម្រួលដែលត្រូវបញ្ចូលទៅក្នុងកំណត់ហេតុផ្លូវការ នៃវិវាទ ។

**ប្រការ ២៦ :-**

ប្រសិនបើភាគីទាំងឡាយ អាចឈានដល់ការព្រមព្រៀងក្នុងពេលសម្រុះសម្រួលដោយគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ អ្នកសម្រុះសម្រួលត្រូវបំពេញបែបបទបញ្ចប់វិវាទដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី ៦ ដែលមានរៀបរាប់អំពីដំណើរការដំណោះស្រាយដោយបញ្ជាក់ច្បាស់លាស់ពីការព្រមព្រៀងដោះស្រាយនោះ ។ រាល់ឯកសារឬផែនទីនានាដែលអាចបំភ្លឺកិច្ចដំណោះស្រាយនោះត្រូវតម្កល់ជាមួយបែបបទបញ្ចប់វិវាទ ។

អ្នកសម្រុះសម្រួល ត្រូវអានដំណោះស្រាយព្រមព្រៀងអោយភាគីទាំងអស់ស្តាប់ ។ ភាគីវិវាទត្រូវចុះហត្ថលេខាឬផ្តិតមេដៃលើកិច្ចព្រមព្រៀងតែក្នុងករណីដែលភាគីនោះយល់ព្រមលើរាល់ចំណុចនៃកិច្ចព្រមព្រៀង ។ កិច្ចព្រមព្រៀងនឹងមានសុពលភាពក្នុងករណីដែលភាគីវិវាទទាំងអស់បានព្រមព្រៀង និងបានចុះហត្ថលេខា ឬ បានផ្តិតមេដៃ ។ ភាគីវិវាទត្រូវចុះហត្ថលេខា ឬផ្តិតមេដៃលើបែបបទបញ្ចប់រឿងក្តីរួចតម្កល់បែបបទនោះនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុកខណ្ឌ។ មន្ត្រីទទួលទម្រង់បែបបទបញ្ចប់រឿងក្តីត្រូវចុះហត្ថលេខា និង បោះត្រាផ្លូវការលើទម្រង់បែបបទនេះហើយត្រូវផ្តល់ដល់ភាគីវិវាទនីមួយៗនូវឯកសារថតចម្លងនៃបែបបទនេះ ។ ច្បាប់ថតចម្លងនៃបែបបទបញ្ចប់រឿងក្តីនេះគឺជាភស្តុតាងនៃការដាក់តម្កល់កិច្ចដំណោះស្រាយ ។

រាល់ឯកសារទាក់ទងទៅនឹងលទ្ធផលនៃការដោះស្រាយវិវាទរួមទាំងបែបបទបញ្ចប់រឿងក្តី សេចក្តីពណ៌នានៃកិច្ចដំណោះស្រាយ និង ផែនទី ឬ គំនូសតាងនានាដែលអាចបំភ្លឺកិច្ចដំណោះស្រាយ ត្រូវបិទផ្សាយជាសាធារណៈដែលមានរយៈពេលមិនតិចជាង ១៤ ថ្ងៃ ។ បុគ្គលណាក៏ដោយក៏អាចបញ្ចេញមតិលើឯកសារបញ្ចប់រឿងក្តីនេះក្នុងអំឡុងពេលប្រកាសផ្សាយជាសាធារណៈ ។

ក្រុមអ្នកសម្រុះសម្រួល ត្រូវរាយការណ៍អំពីកិច្ចដំណោះស្រាយរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក ខណ្ឌ និងគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។ បន្ទាប់មកការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ត្រូវចាប់ផ្តើមនីតិវិធីចុះបញ្ជីក្បាលដីដែលបានដោះស្រាយរួចនោះ ។

**ប្រការ ២៧ :-**

ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ត្រូវបញ្ជាក់អំពីដំណោះស្រាយជាមួយភាគីវិវាទ និងត្រូវចាប់ផ្តើមអនុវត្តនីតិវិធីចុះបញ្ជីក្បាលដីដែលបានដោះស្រាយរួចនោះនៅពេលទទួលបានការបញ្ជាក់ថាដំណោះស្រាយបានសំរេចដោយស្ម័គ្រចិត្ត និង ថាភាគីវិវាទយល់ពីកិច្ចព្រមព្រៀង ។

**ប្រការ ២៨ :-**

ប្រសិនបើភាគីមិនអាចឈានដល់ដំណោះស្រាយ ក្រុមអ្នកសម្រុះសម្រួលត្រូវរៀបចំរបាយការណ៍ស្តីពីដំណើរការសម្រុះសម្រួលអនុលោមតាមបែបបទស្តង់ដារដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី៧ ។ របាយការណ៍ត្រូវរួមបញ្ចូលពត៌មានជាមូលដ្ឋានស្តីពីភាគីវិវាទ សេចក្តីសង្ខេបជំហររបស់ភាគីវិវាទនិងសេចក្តីសង្ខេបអំពីដំណើរការសម្រុះសម្រួល។ របាយការណ៍នេះត្រូវក្លាយជាផ្នែកមួយនៃកំណត់ហេតុសាធារណៈផ្លូវការនៃវិវាទ និង ត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

## ៦. ការសម្រុះសម្រួលរបស់គណៈកម្មការ សុរិយោដីថ្នាក់ខេត្ត ក្រុង

**ប្រការ ២៩ :-**

ករណីសម្រុះសម្រួលជំហានដំបូង រួមមានវិវាទដែលត្រូវបានបញ្ជូនទៅឱ្យគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ដើម្បីធ្វើការសម្រុះសម្រួលដោយផ្ទាល់ដោយអនុលោមតាមប្រការ១៨ និងប្រការ២១ នៃប្រកាសនេះ ។ ករណីសម្រុះ-សម្រួលជំហានដំបូង ត្រូវបានបញ្ជូនអមជាមួយកំណត់ហេតុផ្លូវការពេញលេញនៃវិវាទទៅអោយគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

**ប្រការ ៣០ :-**

ករណីសម្រុះសម្រួលជំហានទី២ រួមមានវិវាទដែលដោះស្រាយមិនបានសំរេចនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ។ ករណីសម្រុះសម្រួលជំហានទី ២ត្រូវបញ្ជូនអមជាមួយកំណត់ហេតុផ្លូវការពេញលេញ និងរបាយការណ៍សម្រុះ-សម្រួលទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

**ប្រការ ៣១ :-**

ក្នុងរយៈពេល ៦០ថ្ងៃ បន្ទាប់ពីបានទទួលបណ្តឹងវិវាទសំរាប់ការសម្រុះសម្រួលជំហានដំបូង ឬ ការសម្រុះសម្រួលជំហានទី២ គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងត្រូវរៀបចំកិច្ចប្រជុំរដ្ឋបាលរវាងគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង និងភាគីវិវាទ។

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង អាចអញ្ជើញតំណាងរបស់អាជ្ញាធរដែនដី ស្រុក ខណ្ឌ ឃុំ សង្កាត់ ឬមន្ទីរជុំវិញខេត្តក្រុងពាក់ព័ន្ធនានាអោយចូលរួមជាសមាជិកអាដហុកដើម្បីសម្រុះសម្រួលវិវាទ ។ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង គប្បីយកចិត្តទុកដាក់បញ្ចូលស្ត្រីជាសមាជិកនៃគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

ក្នុងអំឡុងពេលនៃកិច្ចប្រជុំរដ្ឋបាលដំបូង ភាគីវិវាទត្រូវលើកសំណើ និង ការជំទាស់ចំពោះវិវាទអំពីផលប្រយោជន៍ប្រសិនបើមាន ។ គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវដោះស្រាយរាល់វិវាទអំពីផលប្រយោជន៍ និងកំណត់អ្នកសម្រុះសម្រួលសំរាប់វិវាទនោះ ។ បន្ទាប់មក អ្នកសម្រុះសម្រួលត្រូវជួបជាមួយភាគីវិវាទ និងកំណត់ពេលវេលាសំរាប់អោយភាគីបង្ហាញភស្តុតាងបន្ថែមនានា និង ពេលវេលាសំរាប់សម្រុះសម្រួលវិវាទ។

**ប្រការ ៣២ :-**

ប្រសិនបើសមាជិកណាម្នាក់នៃគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងមានផលប្រយោជន៍ក្នុងវិវាទសមាជិករូបនោះត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទនោះហើយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចតែងតាំងសមាជិកថ្មីជំនួសវិញ ។

ភាគី អាចដាក់ពាក្យបណ្តឹងជំទាស់ជាលាយលក្ខណ៍អក្សរចំពោះការចូលរួមរបស់សមាជិកគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងណាម្នាក់រួមទាំងប្រធានគណៈកម្មការដោយផ្អែកលើមូលដ្ឋាននៃវិវាទអំពីផលប្រយោជន៍របស់សមាជិក ។ សមាជិកដទៃទៀតនៃគណៈកម្មការ ត្រូវសំរេចថាតើសមាជិកដែលត្រូវជំទាស់អំពីវិវាទផលប្រយោជន៍នោះត្រូវរាំងមិនឱ្យសាមីខ្លួនចូលរួមក្នុង ការដោះស្រាយវិវាទឬទេ ។

**ប្រការ ៣៣ :-**

ភាគីទាំងឡាយ អាចជ្រើសរើសអ្នកសម្រុះសម្រួលក្នុងចំណោមសមាជិកអាដហុក និង សមាជិកអចិន្ត្រៃយ៍នៃគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង នៅក្នុងលក្ខខណ្ឌតែមួយគឺ ភាគីវិវាទទាំងអស់ព្រមព្រៀងជាលាយលក្ខណ៍អក្សរចំពោះការប្រើប្រាស់អ្នកសម្រុះសម្រួលនោះ ។ ក្នុងករណីភាគីវិវាទទាំងអស់មិនព្រមព្រៀងលើសមាសភាពអ្នកសម្រុះសម្រួលណាមួយដែលមកពីគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង នោះប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងត្រូវចាត់តាំងក្រុមអ្នកសម្រុះសម្រួលក្នុងចំណោមសមាជិកអាដហុក និង សមាជិកអចិន្ត្រៃយ៍នៃគណៈកម្មការ ។

ក្រុមអ្នកសម្រុះសម្រួលមានសមាជិក ៣រូប ដែលមានម្នាក់ជាប្រធានត្រូវសម្រុះសម្រួលវិវាទ ។ ក្រុមអ្នកសម្រុះសម្រួល យ៉ាងហោចណាស់ត្រូវរួមបញ្ចូលសមាជិកមួយរូបជាអ្នកបានទទួលការបណ្តុះបណ្តាល ឬ មានបទពិសោធន៍ក្នុងការសម្រុះសម្រួលវិវាទ និង សមាជិកមួយរូបជាអ្នកដឹងពីស្ថានភាព និង សភាពការណ៍នៅក្នុងមូលដ្ឋាន ។

**ប្រការ ៣៤ :-**

អ្នកសម្រុះសម្រួលត្រូវធ្វើការសម្រុះសម្រួលនៅលើទីតាំងដី ឬ នៅជិតដីវិវាទ លើកលែងតែមានហេតុផលបញ្ជាក់ថាមានការគំរាមកំហែងដល់សន្តិសុខរបស់មន្ត្រីគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។ ក្នុងករណីអសន្តិសុខដំណើរការសម្រុះសម្រួលវិវាទត្រូវធ្វើឡើងនៅទីកន្លែងដែលមានសន្តិសុខដែលនៅជិតដីវិវាទបំផុត ។

នីតិវិធីរដ្ឋបាលសំរាប់សម្រុះសម្រួលរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវដូចគ្នានឹងនីតិវិធីទាំងឡាយរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដែលមានចែងលំអិតនៅក្នុងប្រការ ២៤ នៃប្រកាសនេះ ។

**ប្រការ ៣៥ :-**

នីតិវិធីរដ្ឋបាលនៃដំណោះស្រាយរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងត្រូវដូចគ្នានឹងនីតិវិធីទាំងឡាយសំរាប់កិច្ចដំណោះស្រាយនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដែលមានចែងលំអិតនៅក្នុង ប្រការ២៦ នៃប្រកាសនេះ ។

អ្នកសម្រុះសម្រួល ត្រូវបញ្ជូនកិច្ចដំណោះស្រាយរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក ខណ្ឌ ដើម្បីចុះបញ្ជីក្បាលដី ។

**ប្រការ ៣៦ :-**

នីតិវិធីរដ្ឋបាលសំរាប់បញ្ជាក់អំពីកិច្ចដំណោះស្រាយដែលសំរេចបាននៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវដូចគ្នានឹងនីតិវិធីទាំងឡាយនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដែលមានចែងលំអិតនៅក្នុងប្រការ ២៧ នៃប្រកាសនេះ ។

**ប្រការ ៣៧ :-**

នីតិវិធីរដ្ឋបាលសំរាប់ការធ្វើរបាយការណ៍សម្រុះសម្រួលនៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវដូចគ្នានឹងនីតិវិធីទាំងឡាយនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដែលមានចែងលំអិតនៅក្នុងប្រការ២៨ នៃ ប្រកាសនេះ ។

## ៧. ដំណើរការដោះស្រាយវិវាទរបស់ គណៈកម្មការសុរិយោដីថ្នាក់ជាតិ

**ប្រការ ៣៨ :-**

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសិទ្ធិសំរេចវិវាទទាំងឡាយដែលស្ថិតនៅក្រៅតំបន់វិនិច្ឆ័យ ហើយដែលមិនអាចដោះស្រាយបានដោយគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ និងគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង និងរាល់វិវាទដែលកើតមាននៅក្នុងតំបន់វិនិច្ឆ័យដែលមិនអាចដោះស្រាយបានដោយគណៈកម្មការរដ្ឋបាល ។

លើកលែងតែក្នុងករណីបន្ទាន់ដូចមានពណ៌នាក្នុងប្រការ៣៩នៃប្រកាសនេះ គណៈកម្មការសុរិយោដីថ្នាក់ជាតិមិនត្រូវពិនិត្យករណីទាំងឡាយក្នុងឋានៈជាក្រុមអ្នកសម្រុះសម្រួលជំហានដំបូងចំពោះករណីវិវាទណាមួយឡើយ ។

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ឬគណៈកម្មការរដ្ឋបាល ត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិនូវករណីវិវាទអមជាមួយកំណត់ហេតុផ្លូវការទាំងមូល និងរបាយការណ៍សម្រុះសម្រួលដែលសង្ខេបដំណើរការវិវាទដែលបានធ្វើនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ និងគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ឬ នៅគណៈកម្មការរដ្ឋបាលតាមករណីជាក់ស្តែង ។

## ប្រការ ៣៩ :-

ក្នុងករណីវិវាទដែលតម្រូវឱ្យមានការសំរេច ឬ ដំណើរការដោះស្រាយជាបន្ទាន់ ដូចជាករណី មានការគំរាមកំហែង ឬការភ័យខ្លាចសមហេតុផលកើតឡើងពីការបង្កអគ្គិភ័យ ការប្រើកំលាំង ឬ ការបំភិតបំភ័យ ភាគីវិវាទអាចស្នើទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិអោយចាត់វិធានការបណ្តោះអាសន្នដើម្បីការពារផលប្រយោជន៍របស់ភាគីនៅពេលដែលវិវាទកំពុងធ្វើការដោះស្រាយ។ ក្នុងស្ថានភាពនេះ ភាគីអាចប្តឹងដោយផ្ទាល់ទៅគណៈកម្មការសុរិយោដីថ្នាក់ ជាតិឱ្យចេញសេចក្តីសំរេចបណ្តោះអាសន្ន ដើម្បីធ្វើអោយស្ថានការណ៍មានស្ថេរភាពរហូតដល់មានការស៊ើបអង្កេត និង សេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ សេចក្តីសំរេចបណ្តោះអាសន្នត្រូវមានខ្លឹមសារជាការរក្សាស្ថានភាពដដែល ។

## ប្រការ ៤០ :-

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវកោះប្រជុំគណៈកម្មការសុរិយោដីថ្នាក់ជាតិ តាមតម្រូវការដើម្បីដោះស្រាយវិវាទ ។

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចអញ្ជើញតំណាងក្រសួង និង ស្ថាប័នពាក់ព័ន្ធអោយចូលរួមជាសមាជិកអាដហុកដើម្បីដោះស្រាយវិវាទ ។ ប្រធានគប្បីយកចិត្តទុកដាក់បញ្ចូលស្ត្រីជាសមាជិកនៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ។

## ប្រការ ៤១ :-

បន្ទាប់ពីត្រួតពិនិត្យមើលកំណត់ហេតុផ្លូវការនៃវិវាទ ឬ នៅពេលផ្សេងទៀតក្នុងអំឡុងពេលធ្វើការពិនិត្យវិវាទដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិអាចសំរេចធ្វើការសម្រុះសម្រួលវិវាទបន្ថែមទៀត ។

នៅក្នុងស្ថានភាពនេះនីតិវិធីរដ្ឋបាលដើម្បីសម្រុះសម្រួលនៅថ្នាក់ជាតិត្រូវអនុវត្តដូចនីតិវិធីទាំងឡាយសំរាប់គណៈ-កម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដូចមានចែងលំអិតក្នុងប្រការ ២៤ នៃប្រកាសនេះ ។

ប្រសិនបើការសម្រុះសម្រួលមិនបានសំរេច ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវកំណត់កាលបរិច្ឆេទសំរាប់ការធ្វើសវនាការដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

ភាគីអាចស្នើសុំគណៈកម្មការសុរិយោដីថ្នាក់ជាតិឱ្យបញ្ជូនក្រុមអ្នកវិនិច្ឆ័យចល័តទៅកាន់ខេត្ត ក្រុង ស្រុក ខណ្ឌ ។ ក្នុងករណីដែលគ្មានការព្រមព្រៀងគ្នារវាងភាគី ទីកន្លែងធ្វើសវនាការត្រូវស្ថិតនៅជិតដីវិវាទបំផុត ។ នៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ គូវិវាទត្រូវកំណត់ពេលវេលាដើម្បីចុះទៅពិនិត្យមើលទីតាំងដីវិវាទ ឬ ព្រមព្រៀងលើកលែងការស៊ើបអង្កេតបន្ថែមទៀតបាន ។

**ប្រការ ៤២ :-**

ប្រសិនបើ សមាជិកណាម្នាក់នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ មានផលប្រយោជន៍នៅក្នុងវិវាទ សមាជិកនោះត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទ ហើយប្រសិនបើចាំបាច់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់អាចតែងតាំងសមាជិកថ្មីជំនួសវិញ ។

ភាគីអាច ដាក់ពាក្យបណ្តឹងជំទាស់ជាលាយលក្ខណ៍អក្សរចំពោះការចូលរួមរបស់សមាជិករួមទាំងប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិដោយផ្អែកលើវិវាទអំពីផលប្រយោជន៍របស់សមាជិកនោះ ។ សមាជិកដទៃទៀតនៃ គណៈកម្មការត្រូវសំរេចថា តើសមាជិកដែលត្រូវជំទាស់អំពីវិវាទអំពីផលប្រយោជន៍នោះត្រូវរាំងមិនអោយចូលរួមក្នុងការដោះស្រាយវិវាទ ឬ ទេ ។

**ប្រការ ៤៣ :-**

រាល់កិច្ចប្រជុំ ឬសវនាការដែលគណៈកម្មការសុរិយោដីថ្នាក់ជាតិចាត់វិធានការផ្លូវការទាក់ទងទៅនឹងវិវាទត្រូវបើកចំហជាសាធារណៈ ។

សេចក្តីជូនដំណឹងជាមុនអំពីរាល់កិច្ចប្រជុំ ឬ សវនាការដែលជាការចាត់វិធានការផ្លូវការត្រូវជូនដល់សាធារណជននិង ប្រព័ន្ធសារពត៌មាន ។ លេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវរក្សាទុកកំណត់ហេតុនៃដំណើរការរឿងវិវាទទាំងអស់របស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ហើយបុគ្គលណាក៏មានសិទ្ធិមើលកំណត់ហេតុទាំងនោះទោះបីបុគ្គលនោះមាន ឬគ្មានផលប្រយោជន៍នៅក្នុងវិវាទនោះក្តី ។

**ប្រការ ៤៤ :-**

លើកលែង តែការប្រជុំសំរាប់ការសម្រុះសម្រួលដែលអាចធ្វើឡើងជាមួយភាគីវិវាទដោយឡែកពីគ្នា គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវអញ្ជើញភាគីដែលមានផលប្រយោជន៍ទាំងអស់ឱ្យចូលរួមរាល់កិច្ចប្រជុំ និងសវនាការទាក់ទងទៅនឹងវិវាទរបស់ពួកគេ ។ សេចក្តីអញ្ជើញ ត្រូវបញ្ជូនទៅអោយភាគី យ៉ាងហោច ១៥ ថ្ងៃនៃថ្ងៃធ្វើការមុនពេលបើកកិច្ចប្រជុំ ឬ សវនាការ ។

**ប្រការ ៤៥ :-**

ភាគី អាចជ្រើសរើសបុគ្គលម្នាក់តាមជំរើសរបស់ខ្លួនផ្ទាល់ អោយតំណាងខ្លួននៅក្នុងរាល់ដំណើរការ នៃរឿងវិវាទ របស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ បុគ្គលនេះហៅថាអ្នកការពារក្តី អាចផ្តល់ការណែនាំ ឬអាចតំណាងភាគីបាន។ អ្នកការពារក្តីអាចបញ្ជាក់ពីចម្លើយរបស់ភាគី និងអាចចូលរួមកិច្ចប្រជុំជាមួយគណៈកម្មការសុរិយោដីថ្នាក់ជាតិហើយតាមការយល់ព្រមរបស់ភាគីអាចនិយាយ និងអាចធ្វើសេចក្តីសំរេចក្នុងនាមភាគីបាន ។ ទោះបីជាយ៉ាងណាក្តីបើគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាក់លាក់របស់ភាគីទេនោះ អ្នកការពារក្តីមិនអាចដោះស្រាយវិវាទក្នុងនាមភាគីបានឡើយ ។

ប្រសិនបើ អ្នកការពារក្តីបំពានវិធាននៃដំណើរការរឿងវិវាទ គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវផ្តល់ការក្រើនរំលឹក និងការព្រមានជាឯកជនម្តងដល់អ្នកការពារក្តី ។ ប្រសិនបើ អ្នកការពារក្តីនៅតែបន្តបំពានទៀតគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវហាមឃាត់អ្នកការពារក្តីនោះមិនឱ្យចូលរួមក្នុងដំណើរដោះស្រាយវិវាទទៀតឡើយ ។ ប្រសិនបើអ្នកការពារក្តីត្រូវបានហាមឃាត់មិនឱ្យចូលរួម ដំណើរការរឿងវិវាទនោះត្រូវផ្អាក រហូតដល់ភាគីជ្រើសរើសអ្នកការពារក្តីថ្មីបានឬយល់ព្រមឱ្យបន្តដំណើរការដោយមិនមានអ្នកការពារក្តី។ គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវផ្តល់ឱកាសគ្រប់គ្រាន់ដល់ភាគីដើម្បីពិគ្រោះយោបល់ជាមួយអ្នកការពារក្តីដែលត្រូវបានហាមឃាត់អោយនៅក្រៅកន្លែងដោះស្រាយ ។

**ប្រការ ៤៦ :-**

គណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចធ្វើសវនាការវិវាទជាក្រុមវិនិច្ឆ័យ ឬ អាចតែងតាំងសមាជិកតែម្នាក់ ឬមន្ត្រីសវនា ការតែមួយរូបឱ្យធ្វើសវនាការបាន ។

រាល់សវនាការ សក្ខីកម្មផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរអាចទទួលយកបាន ។

គណៈកម្មការសុរិយោដីថ្នាក់ ជាតិ មិនត្រូវបានតម្រូវអោយគោរពតាមវិធានភស្តុតាង ឬនីតិវិធីផ្លូវការទេ ប៉ុន្តែត្រូវធានាឱ្យភាគីទាំងអស់មានឱកាសបង្ហាញសក្ខីកម្ម និង ភស្តុតាងរបស់ខ្លួនដោយយុត្តិធម៌ និង សមធម៌ ។

ភាគីនីមួយៗមានសិទ្ធិបង្ហាញសាក្សី និងបដិសេធភស្តុតាង ឬសាក្សីដែលផ្តល់ដោយភាគីផ្សេងទៀត ។ បុគ្គលដែលផ្តល់សក្ខីកម្មអាចត្រូវបានតម្រូវអោយឆ្លើយនឹងសំនួរបញ្ជាក់អំពីសក្ខីកម្មនោះ ។

**ប្រការ ៤៧ :-**

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវស្តាប់ភស្តុតាងវិវាទ និង ត្រួតពិនិត្យឯកសារផ្លូវការនៃវិវាទដែលបានប្រមូលនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ឬ គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ឬ ដោយគណៈកម្មការរដ្ឋបាល ហើយត្រូវចេញសេចក្តីសំរេចដែលមានប្រសិទ្ធភាពអនុវត្តដោយផ្អែកលើរបាយការណ៍នេះ

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវចេញសេចក្តីសំរេចនៅពេលធ្វើការសរុបសន្និដ្ឋានការពិភាក្សារបស់ខ្លួនហើយត្រូវធ្វើកំណត់សំគាល់សេចក្តីសន្និដ្ឋានខាងផ្លូវច្បាប់ និង មូលដ្ឋានអង្គហេតុនៃសេចក្តីសំរេចរបស់ខ្លួន ។ សេចក្តីសំរេចស្ថាពរត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និង ចុះហត្ថលេខាដោយប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

សេចក្តីសំរេចជាលាយលក្ខណ៍អក្សររបស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវផ្ញើអោយភាគីទាំងឡាយតាមរយៈសំបុត្រប្រៃសណីយ៍ និងត្រូវបើកចំហសំរាប់ការពិនិត្យមើលជាសាធារណៈដល់បុគ្គលណាក៏ដោយទោះបីមាន ឬ គ្មានផលប្រយោជន៍នៅក្នុងរឿងវិវាទនោះក្តី ។

សេចក្តីសំរេចជាលាយលក្ខណ៍អក្សរ ត្រូវអមជាមួយសេចក្តីជូនដំណឹងដែលជំរាបភាគីវិវាទអំពីសិទ្ធិរបស់ពួកគេក្នុងការប្តឹងតវ៉ាទៅតុលាការឱ្យពិនិត្យមើលឡើងវិញផ្នែកច្បាប់ ចំពោះសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ហើយត្រូវផ្តល់ពត៌មានអំពីរបៀបប្តឹងទៅតុលាការផង ។

## ប្រការ ៤៨ :-

សេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិក្លាយជាសេចក្តីសំរេចស្ថាពរនៅក្រោយ រយៈពេល ៣០ ថ្ងៃ បន្ទាប់ពីសេចក្តីសំរេចនោះត្រូវបានបញ្ជូនទៅដល់ភាគីវិវាទទាំងអស់ លើកលែងតែករណីមានការប្តឹងទៅតុលាការ ឬមានការស្នើសុំ ឱ្យធ្វើការពិនិត្យឡើងវិញដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិ អនុលោមតាមប្រការ ៤៩ នៃប្រកាសនេះ។

ប្រសិនបើគ្មានការប្តឹងតវ៉ាទៅតុលាការ ឬ គ្មានការស្នើសុំអោយធ្វើសវនាការឡើងវិញត្រូវបានធ្វើឡើងតាមពេលវេលាត្រឹមត្រូវទេលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវបញ្ជូនសេចក្តីសំរេចនោះទៅការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក ខណ្ឌ។ បន្ទាប់មក ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក ខណ្ឌ ត្រូវចាប់ផ្តើមអនុវត្តនីតិវិធីចុះបញ្ជីក្បាលដីដែលត្រូវបានសំរេចនោះ។

## ប្រការ ៤៩ :-

ការធ្វើសវនាការឡើងវិញពុំអាចធ្វើបានទេ លើកលែងតែមានសម្លេងយល់ព្រមពីសមាជិក ៣ រូប នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ នៅពេលដែលមានភស្តុតាងថ្មីធំដុំត្រូវបានដាក់ជូនគណៈកម្មការ ។

សំណើសុំធ្វើសវនាការឡើងវិញ ត្រូវដាក់ជូនជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីសេចក្តីសំរេចជាលាយលក្ខណ៍អក្សរត្រូវបានបញ្ជូនទៅដល់ភាគី ហើយត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនោះដោយត្រូវអមដោយពត៌-មាននិងគំនូសតាងចាំបាច់នានា ។

ការធ្វើសវនាការឡើងវិញ ត្រូវអនុលោមតាមសេចក្តីជូនដំណឹង និង លក្ខខណ្ឌតម្រូវផ្នែកនីតិវិធីដូចសវនាការដើមដែរ ។

ប្រសិនបើមានការបដិសេធចំពោះសំណើសុំអោយមានសវនាការឡើងវិញ គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបដិសេធនោះដល់ភាគីវិវាទ ។ នៅក្នុងករណីនេះសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ក្លាយជាស្ថាពរក្រោយបញ្ចប់រយៈពេល៣០ថ្ងៃ បន្ទាប់ពីសេចក្តីជូនដំណឹងពីការបដិសេធត្រូវបានបញ្ជូនទៅដល់ភាគីវិវាទលើកលែងតែភាគីម្ខាងនៃគូវិវាទជូនដំណឹងអំពីការប្តឹងជំទាស់ទៅតុលាការតាមពេលវេលាត្រឹមត្រូវ ។

**ប្រការ ៥០ :-**

ភាគីណាក៏ដោយអាចប្តឹងទៅតុលាការដោយរួមគ្នា ឬជាបុគ្គលអំពីសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ បណ្តឹងជំទាស់ត្រូវដាក់ជូនទៅតុលាការក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីសេចក្តីសំរេចជាលាយលក្ខណ៍អក្សររបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវបានបញ្ជូនដល់ភាគីវិវាទ ។

ភាគីណាមួយដែលធ្វើបណ្តឹងទៅតុលាការ ត្រូវដាក់តម្កល់ឯកសារថតចម្លងមួយច្បាប់នៃបណ្តឹងជំទាស់នៅលេខាធិការដ្ឋាន នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

លេខាធិការដ្ឋាន ត្រូវធ្វើសេចក្តីបញ្ជាក់ជាបន្ទាន់នូវរបាយការណ៍ផ្លូវការដើម្បីបញ្ជូនទៅតុលាការ ។

## ៨. បទប្បញ្ញត្តិរដ្ឋបាល

**ប្រការ ៥១ :-**

ប្រធានគណៈកម្មការសុរិយោដីគ្រប់ថ្នាក់ ត្រូវធ្វើរបាយការណ៍ប្រចាំខែ ស្តីពីបណ្តឹងដែលបានទទួល និង ចំណាត់ការដែលបានធ្វើដោយគណៈកម្មការចំពោះបណ្តឹងនីមួយៗ ដែលគណៈកម្មការបានធ្វើ ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍ប្រចាំខែទៅ គណៈកម្មការសុរិយោដីថ្នាក់ខេត្តក្រុង ។

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវធ្វើរបាយការណ៍ប្រចាំខែទៅ គណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវធ្វើរបាយការណ៍ប្រចាំខែទៅ រាជរដ្ឋាភិបាល ។

របាយការណ៍របស់គណៈកម្មការសុរិយោដី ត្រូវបើកចំហ និង អនុញ្ញាតឱ្យសាធារណជនមើលដោយសេរីក្នុងពេលម៉ោងធ្វើការធម្មតា ។

**ប្រការ ៥២ :-**

គណៈកម្មការសុរិយោដីគ្រប់ថ្នាក់ ត្រូវរក្សាទុកកំណត់ហេតុផ្លូវការនៃវិវាទនីមួយៗដែលបានប្តឹងនៅគណៈកម្មការនោះ ។

កំណត់ហេតុផ្លូវការ ត្រូវរួមបញ្ចូលរាល់ឯកសារទាំងអស់ សេចក្តីអះអាងភស្តុតាងផ្សេងៗ និងរបាយការណ៍ផ្សេងៗ ទាក់ទងទៅនឹងវិវាទ ។

ឯកសារផ្លូវការត្រូវបើកចំហជាសាធារណៈ និង អនុញ្ញាតឱ្យសាធារណជនចូលមើលដោយសេរីក្នុងពេលម៉ោងធ្វើការធម្មតា។

បុគ្គលទាំងឡាយដែលចង់ពិនិត្យមើលឯកសារ ត្រូវទៅមើលនៅការិយាល័យគណៈកម្មការសុរិយោដីនោះ និងត្រូវចុះហត្ថលេខាលើសៀវភៅភ្ញៀវ ។

នៅកន្លែងដែលមានសម្ភារៈបរិក្ខារថតចម្លង បុគ្គលទាំងឡាយអាចថតចម្លងឯកសារបាន ។

**ប្រការ ៥៣ :-**

នាយកខុទ្ទកាល័យ ប្រធានគណៈកម្មការសុរិយោដីគ្រប់ថ្នាក់ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង និង ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក ខណ្ឌ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២

រដ្ឋមន្ត្រី

អ៊ឹម ឈុនលឹម

**កន្លែងទទួល :**

ទីស្តីការគណៈរដ្ឋមន្ត្រី

គ្រប់ក្រសួង ស្ថាប័ន

គ្រប់សាលាខេត្ត ក្រុង

ដូចប្រការ ៥៣

ឯកសារ កាលប្បវត្តិ